ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:...១៣១...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## លក្ខខណ្ឌ និងវិធានការនានា ស្តីពីការបង្ការ និងការពន្លត់អគ្គិភ័យ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០០៧ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្ការ និងការពន្លត់អគ្គិភ័យ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលបំណងកំណត់អំពីការគ្រប់គ្រងការបង្ការ និងពន្លត់អគ្គិភ័យ ឱ្យមានប្រសិទ្ធភាពខ្ពស់លើការស្តុកទុក ការដឹកជញ្ជូន ការលក់ ការផលិត ការកែច្នៃ ការប្រើប្រាស់សារធាតុ ងាយឆេះ ឬងាយផ្ទុះឆេះ ប្រភពភ្លើង និងប្រភពកម្តៅដែលអាចបង្កឱ្យមានអគ្គិភ័យ ។

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីលក្ខខណ្ឌ និងវិធានការនានាស្តីពីការបង្ការ និងការពន្លត់អគ្គិភ័យ សំដៅការពារអាយុជីវិត ទ្រព្យសម្បត្តិ បរិស្ថាន សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ។

**មាត្រា៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះគ្រប់សកម្មភាពការបង្ការ និងពន្លត់អគ្គិភ័យ នៃការស្តុកទុក ការដឹកជញ្ជូន ការគ្រប់គ្រង ការលក់ ការកែច្នៃ ការប្រើប្រាស់សារធាតុងាយឆេះ ឬងាយផ្ទុះឆេះ ប្រភពភ្លើង ប្រភពកម្តៅដែលអាចបង្កឱ្យកើតមានអគ្គិភ័យ។

**មាត្រា៤.-**

វាក្យស័ព្ទសំខាន់ៗដែលមានប្រើក្នុងច្បាប់ស្តីពីការបង្ការ និងការពន្លត់អគ្គិភ័យត្រូវបានប្រើក្នុងអនុក្រឹត្យនេះមាននិយមន័យដូចខាងក្រោម ៖

- ប្រភពភ្លើង ឬប្រភពកម្តៅ សំដៅដល់ភ្លើងចង្ក្រាន ភ្លើងចង្កៀង ភ្លើងបារី ភ្លើងផ្សារដែក ភ្លើងទៀនធូប ភ្លើងសំរាម ភ្នក់ភ្លើង រងើកភ្លើង ភ្លើងព្រៃ ភ្លើងចរន្តអគ្គិសនី ផ្កាំងអ៊ុត ឡកម្តៅ ធុងកម្តៅទឹក វត្ថុអាចប្រតិកម្មនឹងចំណាំងពន្លឺ ឧបករណ៍សម្ភារ ឬសារធាតុមួយចំនួនដែលមានប្រតិកម្មទៅនឹងវត្ថុដទៃទៀតបង្កើតបានជាកម្តៅ ឬភ្លើង ឬឆេះ ឬផ្ទុះឆេះ
- សារធាតុងាយឆេះ ឬងាយផ្ទុះឆេះ សំដៅដល់សារធាតុរាវ រឹង ឧស្ម័ន គីមី ទំនិញ ឬវត្ថុធាតុដើម ដែលងាយឆេះ ឬងាយផ្ទុះឆេះ
- លក្ខខណ្ឌ និងវិធាន សំដៅដល់លក្ខខណ្ឌតម្រូវសម្រាប់ការរៀបចំប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ ជានាសុវត្ថិភាពកុំឱ្យមានអគ្គិភ័យកើតឡើង
- អ្នកទទួលខុសត្រូវតាមគោលដៅ សំដៅដល់នីតិបុគ្គល ឬរូបវន្តបុគ្គលដែលមានតួនាទីគ្រប់គ្រងនៅកន្លែងនានា និងមធ្យោបាយដឹកជញ្ជូនទាំងឡាយណាដែលអាចបង្កឱ្យមានអគ្គិភ័យកើតឡើង
- ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ សំដៅដល់ការបំពាក់ឧបករណ៍បច្ចេកទេសក្នុង និង/ឬក្រៅគោលដៅ ដើម្បីត្រៀមទប់ស្កាត់ និងពន្លត់ពេលមានអគ្គិភ័យកើតឡើង
- ក្រុមបង្ការ និងពន្លត់អគ្គិភ័យកាតព្វកិច្ច សំដៅដល់ក្រុមមនុស្សដែលបង្កើតឡើងជាជំនួយបឋមសម្រាប់ប្រតិបត្តិការបង្ការពន្លត់អគ្គិភ័យ និងសង្គ្រោះនៅតាមគោលដៅដែលមានប្រព័ន្ធបង្ការ

- ក្រុមបង្ការ និងពន្លត់អគ្គិភ័យស្ម័គ្រចិត្ត សំដៅដល់ក្រុមមនុស្សដែលបង្កើតឡើងជាជំនួយបឋមសម្រាប់ប្រតិបត្តិការបង្ការពន្លត់អគ្គិភ័យ និងសង្គ្រោះនៅតាមភូមិ ឃុំ សង្កាត់ ឬសហគមន៍ដែលខ្លួនរស់នៅ

- ទីប្រជុំជន សំដៅដល់ទីកន្លែងដែលមានអគារ ឬគេហដ្ឋានសង់ជិតៗគ្នា ហើយមានប្រជាពលរដ្ឋរស់នៅច្រើន

- អ្នកគ្រប់គ្រងគោលដៅ សំដៅដល់កម្មសិទ្ធិករ អ្នកកាន់កាប់ អភិបាល អ្នកទទួលសិទ្ធិ និង/ឬបុគ្គលទាំងឡាយដែលមានសិទ្ធិគ្រប់គ្រង និងត្រួតពិនិត្យគោលដៅ។

## ជំពូកទី២
## សមត្ថកិច្ចគ្រប់គ្រង និងត្រួតពិនិត្យ

**មាត្រា៥.-**

កិច្ចប្រតិបត្តិការបង្ការ និងពន្លត់អគ្គិភ័យ ការត្រួតពិនិត្យ ការបញ្ជាក់ទទួលស្គាល់ប្រព័ន្ធបង្ការអគ្គិភ័យលើគោលដៅ ការផ្អាកសកម្មភាពបណ្តោះអាសន្នដល់គោលដៅ ឬសកម្មភាពណាដែលខ្វះលក្ខខណ្ឌ និងវិធានបង្ការ និងពន្លត់អគ្គិភ័យ ការពិនិត្យអង្កេតកន្លែងកើតហេតុ ការធ្វើកោសលវិច័យ ជាសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ ដែលមានអគ្គស្នងការដ្ឋាននគរបាលជាតិជាសេនាធិការ។

បែបបទ និងនីតិវិធីនៃការត្រួតពិនិត្យ ការចេញសេចក្តីបញ្ជាក់អំពីគុណភាព ប្រសិទ្ធភាពនៃប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា៦.-**

ការត្រួតពិនិត្យលើការស្តុកទុក ការដឹកជញ្ជូន ការគ្រប់គ្រង ការលក់ ការប្រើប្រាស់សារធាតុងាយឆេះ ឬងាយផ្ទុះឆេះ ប្រភពភ្លើង ប្រភពកម្តៅ និងការអនុវត្តលក្ខខណ្ឌ និងវិធាននានា ស្តីពីការបង្ការ និងការពន្លត់អគ្គិភ័យជាសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃដែលមានអគ្គស្នងការដ្ឋាននគរបាលជាតិជាសេនាធិការ។

**មាត្រា៧.-**

ការត្រួតពិនិត្យការផលិត ការកែច្នៃសារធាតុងាយឆេះ ឬងាយផ្ទុះឆេះ ជាសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃសហការជាមួយក្រសួងពាក់ព័ន្ធ។

**មាត្រា៨.-**

រាល់ការនាំចូលឧបករណ៍សម្ភារបរិក្ខារបង្ការ និងពន្លត់អគ្គិភ័យត្រូវមានការអនុញ្ញាតពីក្រសួងមហាផ្ទៃ។

បែបបទ និងនីតិវិធីនៃការនាំចូលឧបករណ៍សម្ភារបរិក្ខារបង្ការ និងពន្លត់អគ្គិភ័យ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ជំពូកទី៣
## លក្ខខណ្ឌ និងវិធានបង្ការអគ្គិភ័យ

**មាត្រា៩.-**

អ្នកគ្រប់គ្រងគោលដៅទីកន្លែងផលិតកែច្នៃ និង/ឬស្តុកទុកសារធាតុងាយឆេះ ឬងាយផ្ទុះឆេះ ប្រភពភ្លើង និងប្រភពកម្តៅ ត្រូវគោរពតាមលក្ខខណ្ឌ និងវិធានដូចខាងក្រោម ៖

- បទកំណត់ផ្ទៃក្នុងរបស់ខ្លួនស្តីពីការបង្ការ និងការពន្លត់អគ្គិភ័យ

- ត្រូវមានវិញ្ញាបនបត្របញ្ជាក់អំពីការហ្វឹកហ្វឺនជំនាញបង្ការ និងពន្លត់អគ្គិភ័យដូចមានចែងក្នុងមាត្រា ១៥ នៃច្បាប់ស្តីពីការបង្ការ និងការពន្លត់អគ្គិភ័យ

- មានក្រុមបង្ការ និងពន្លត់អគ្គិភ័យកាតព្វកិច្ចដែលបានហ្វឹកហ្វឺន និងមានជំនាញបង្ការ និងពន្លត់អគ្គិភ័យ មានវិញ្ញាបនបត្របញ្ជាក់អំពីគុណភាពប្រសិទ្ធភាពនៃប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យដូចមានចែងក្នុងមាត្រា ១៩ នៃច្បាប់ស្តីពីការបង្ការ និងការពន្លត់អគ្គិភ័យ

- មានធានារ៉ាប់រងចំពោះតតិយជន ដែលរងគ្រោះថ្នាក់ដោយអគ្គិភ័យ ដែលមានតម្លៃធានាស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន

- សង់ជញ្ជាំង ឬរបាំងធ្វើអំពីវត្ថុដែលធន់នឹងភ្លើង ឬធ្វើអំពីសារធាតុមិនងាយឆេះដែលអាចទប់កម្តៅ ឬពន្យារការឆាបឆេះបាន

- ការស្តុកទុកសារធាតុងាយឆេះ ឬងាយផ្ទុះឆេះដែលមានបរិមាណចាប់ពី ១.០០០ (មួយពាន់) លីត្រឡើងទៅត្រូវរៀបចំកប់ទៅក្នុងដីឱ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសឧបករណ៍ សម្ភារ បរិក្ខារស្តុកទុក ត្រូវមានគុណភាពល្អ

- ការស្តុកទុកសារធាតុងាយឆេះ ឬងាយផ្ទុះឆេះដែលមានបរិមាណចាប់ពី ១០.០០០ (មួយម៉ឺន) លីត្រឡើងទៅ ម្ចាស់គោលដៅនីមួយៗ ត្រូវរៀបចំប្រព័ន្ធបញ្ចេញសារធាតុងាយឆេះ ឬងាយផ្ទុះឆេះពេលមានហានិភ័យ

- សាងសង់ទំនប់ព័ទ្ធជុំវិញពាងស្តុកដាក់លើដីឱ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស

- បំពាក់ប្រព័ន្ធប្រកាសអាសន្ន ប្រព័ន្ធវិនិច្ឆ័យចំហាយប្រេងឥន្ធនៈ ឬចំហាយឧស្ម័នចំហេះ ដែលលេចធ្លាយតាមបំពង់បង្ហូរប្រេង ស៊ីទែនកប់ក្នុងដី និងប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យដោយស្វ័យប្រវត្តិ

- មានឧបករណ៍ស្រូបផ្សែង ស្រូបកម្តៅ ម៉ាស៊ីនបាញ់ទឹកពន្លត់អគ្គិភ័យស្វ័យប្រវត្តិ បំពង់ពន្លត់អគ្គិភ័យគ្រប់ប្រភេទ ប្រព័ន្ធទឹកដើរដោយស្វ័យប្រវត្តិសម្រាប់ពន្លត់អគ្គិភ័យ បង្គោលទឹកសម្រាប់ផ្តល់ឱ្យរថយន្តពន្លត់អគ្គិភ័យ និងមានប្រព័ន្ធការពាររន្ទះ

- ផ្លូវចេញ-ចូលសម្រាប់រថយន្តពន្លត់អគ្គិភ័យ ច្រកសម្រាប់សង្គ្រោះ និងជម្លៀស មានស្លាកសញ្ញា ហាមប្រើភ្លើង និងស្លាកសញ្ញាបង្ការគ្រោះថ្នាក់ផ្សេងៗទៀត

- ស្ថិតនៅឆ្ងាយពីទីប្រជុំជន មន្ទីរពេទ្យសាលារៀន ផ្សារ រោងចក្រ សហគ្រាស និង/ឬអង្គភាពកងកម្លាំងប្រដាប់អាវុធទៅតាមទំហំនៃបរិមាណស្តុកទុក យ៉ាងតិចចម្ងាយ ១០០ម៉ែត្រ

- បិទស្លាកសញ្ញាបង្ហាញចំណុចដាក់ឧបករណ៍ពន្លត់អគ្គិភ័យ និងប្រព័ន្ធផ្តល់ទឹកដែលអាចមើលឃើញយ៉ាងច្បាស់ ហើយអាចនាំយកទៅប្រើប្រាស់បានទាន់ពេលវេលា

- មានផែនការបង្ការ និងពន្លត់អគ្គិភ័យតាមគោលដៅនីមួយៗ

- មានផែនការសង្គ្រោះ និងជម្លៀសដោយអនុលោមតាមអនុក្រឹត្យលេខ ១៦៧ អនក្រ.បក ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨ ស្តីពីបែបបទក្នុងការជម្លៀសសាធារណជនចេញពីកន្លែងដែលអាចមានគ្រោះថ្នាក់កើតឡើង

- ហាមជក់បារី ដុតសំរាម ប្រើប្រាស់ភ្លើង ប្រើប្រាស់ទូរស័ព្ទ ឬវត្ថុផ្សេងៗដែលអាចប្រតិកម្មបង្កើតបានជាប្រភពភ្លើង និងប្រភពកម្តៅ នៅក្បែរគោលដៅស្តុកសារធាតុងាយឆេះ និងងាយផ្ទុះឆេះ

- ហាមផ្ទេរសារធាតុងាយឆេះ និងងាយផ្ទុះឆេះ ពេលមានភ្លៀង

- ហាមយកលំនៅដ្ឋានធ្វើជាឃ្លាំងស្តុក សារធាតុងាយឆេះ និងងាយផ្ទុះឆេះ

- មានឧបករណ៍ ឬប្រព័ន្ធជំនួយដើម្បីរក្សាសីតុណ្ហភាពឱ្យនៅក្រោម ៣៧°C និងមានបរិស្ថានល្អ ។

**មាត្រា១០.-**

រាល់មធ្យោបាយដឹកជញ្ជូនសារធាតុងាយឆេះ ងាយផ្ទុះឆេះ ប្រភពភ្លើង ឬប្រភពកម្តៅ ត្រូវគោរពតាមលក្ខខណ្ឌ និងវិធានដូចខាងក្រោម ៖

- ការដឹកជញ្ជូនសារធាតុងាយឆេះ ឬងាយផ្ទុះឆេះដោយរថយន្ត និងរថភ្លើងត្រូវបំពាក់ខ្សែម៉ាស់ដីដែលអាចការពារបាននូវគ្រោះអគ្គិភ័យបង្កឡើងដោយបាតុភូត អេឡិចត្រូស្តាទិចជាដាច់ខាត។ លើកលែងតែការដឹកជញ្ជូនតាមនាវា

- ការចូលចត និងការផ្ទេរសារធាតុងាយឆេះ ឬងាយផ្ទុះឆេះដោយរថយន្តរថភ្លើង និងតាមនាវាត្រូវបំពាក់ខ្សែម៉ាស់ដីដែលអាចការពារបាននូវគ្រោះអគ្គិភ័យបង្កឡើងដោយបាតុភូត អេឡិចត្រូស្តាទិចជាដាច់ខាត

- មានវិញ្ញាបនបត្របញ្ជាក់អំពីគុណភាពប្រសិទ្ធភាពនៃប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ

- បរិមាណផ្ទុកប្រេងឥន្ធនៈឧស្ម័នចំហេះសារធាតុងាយឆេះ ងាយផ្ទុះឆេះក្នុងស៊ីទែនចល័តត្រូវមានកម្រិតកំណត់តាមលក្ខណៈបច្ចេកទេស

- រាល់ការដឹកជញ្ជូនប្រេងឥន្ធនៈឧស្ម័នចំហេះសារធាតុងាយឆេះ ងាយផ្ទុះឆេះមានលក្ខណៈជាធុង ត្រូវចងរឹតឱ្យជាប់នឹងសៀតស្នៀតឱ្យណែនតាមចន្លោះធុង ជៀសវាងមានការកកិតគ្នាអាចបង្កើតប្រភពភ្លើង ឬប្រភពកម្តៅបង្កជាអគ្គិភ័យ

- ត្រូវមានការត្រួតពិនិត្យពេលផ្ទេរសារធាតុ ងាយឆេះ ងាយផ្ទុះឆេះ ប្រភពភ្លើង ឬប្រភពកម្តៅ

- អ្នកគ្រប់គ្រង អ្នកបើកបរមធ្យោបាយដឹកជញ្ជូនប្រេងឥន្ធនៈ ឧស្ម័នចំហេះ សារធាតុងាយឆេះ ងាយផ្ទុះឆេះ ប្រភពភ្លើង ឬប្រភពកម្តៅ ត្រូវទទួលបានការហ្វឹកហ្វឺន មានវិញ្ញាបនបត្របញ្ជាក់ជំនាញបង្ការ និងពន្លត់អគ្គិភ័យពីអង្គភាពបង្ការ ពន្លត់អគ្គិភ័យ និងសង្គ្រោះ

- រាល់មធ្យោបាយដឹកជញ្ជូនប្រេងឥន្ធនៈ ឧស្ម័នចំហេះ សារធាតុងាយឆេះ ងាយផ្ទុះឆេះ ប្រភពភ្លើង ឬប្រភពកម្តៅមិនមែនជាមធ្យោបាយកែច្នៃ ជាមធ្យោបាយផលិតឡើងសម្រាប់តែដឹកជញ្ជូនសារធាតុងាយឆេះ ឬងាយផ្ទុះឆេះ ដោយបំពាក់ប្រព័ន្ធតាមដាននិយាមការ (ជីភីអេស) ឧបករណ៍ពន្លត់អគ្គិភ័យ និងខ្សែម៉ាសចម្លងចរន្ត និងត្រូវមានស្លាកសញ្ញា លិខិតបញ្ជាក់ពីអង្គភាពនគរបាលបង្ការ ពន្លត់អគ្គិភ័យ និងសង្គ្រោះ

- រាល់មធ្យោបាយពេលចត ពេលផ្ទេរត្រូវបែរមុខយានយន្តចេញក្រៅ ពន្លត់ម៉ាស៊ីនយានយន្ត ដាក់បង្គោលមានរាងជាសាជីការពារ ឬព័ទ្ធខ្សែជុំវិញ និងត្រូវភ្ជាប់ខ្សែម៉ាស់ដី ដែលអាចការពារបាននូវគ្រោះអគ្គិភ័យបង្កឡើងដោយបាតុភូត អេឡិចត្រូស្តាទិចជាដាច់ខាតពីតួរថយន្តភ្ជាប់ទៅដី

- ហាមដឹកជញ្ជូនប្រេងឥន្ធនៈ ឧស្ម័នចំហេះសារធាតុងាយឆេះ ងាយផ្ទុះឆេះ ប្រភពភ្លើង ឬប្រភពកម្តៅចូលទីប្រជុំជននៅពេលថ្ងៃ និង/ឬកន្លែងដែលមានពិធីប្រមូលផ្តុំមហាជន ឬកិច្ចប្រជុំនៅតាមស្ថាប័នជាតិធំៗ ឬបុណ្យជាតិ និងអន្តរជាតិ ។

**មាត្រា១១.-**

អ្នកគ្រប់គ្រងគោលដៅ គ្រប់ស្ថានីយលក់ប្រេងឥន្ធនៈ និង/ឬឧស្ម័នចំហេះត្រូវគោរពតាមលក្ខខណ្ឌ និងវិធានដូចខាងក្រោម ៖

- មានបទកំណត់ផ្ទៃក្នុងរបស់ខ្លួនស្តីពីការបង្ការ និងការពន្លត់អគ្គិភ័យ

- មានវិញ្ញាបនបត្រទទួលស្គាល់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យដូចមានចែងក្នុងមាត្រា១៩ នៃច្បាប់ស្តីពីការបង្ការ និងការពន្លត់អគ្គិភ័យ

- មានជានាវ៉ាប់រងចំពោះតតិយជនដោយគ្រោះថ្នាក់អគ្គិភ័យ ដែលមានតម្លៃធានាមិនតិចជាងតម្លៃនៃទ្រព្យដែលឋិតនៅជុំវិញគោលដៅ

- ត្រូវមានវិញ្ញាបនបត្របញ្ជាក់អំពីការហ្វឹកហ្វឺនជំនាញបង្ការ និងពន្លត់អគ្គិភ័យ ដូចមានចែងក្នុងមាត្រា ១៥ នៃច្បាប់ស្តីពីការបង្ការ និងការពន្លត់អគ្គិភ័យ

- មានក្រុមបង្ការ និងពន្លត់អគ្គិភ័យកាតព្វកិច្ច

- សង់ជញ្ជាំង ឬរបាំងធ្វើអំពីវត្ថុដែលធន់នឹងភ្លើង ឬធ្វើអំពីសារធាតុមិនងាយឆេះដែលអាចទប់កម្តៅ ឬពន្យារការឆាបឆេះ និងមានកម្ពស់យ៉ាងតិច ៣ម៉ែត្រ

- ស្ថានីយនីមួយៗត្រូវរៀបចំប្រព័ន្ធបញ្ចេញប្រេងឥន្ធនៈ និង/ឬឧស្ម័នចំហេះពេលមានហានិភ័យ

- ពាង ឬស៊ីទែនប្រេងឥន្ធនៈ ឬឧស្ម័នចំហេះត្រូវរៀបចំទុកដាក់ឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ជៀសវាងការលេចធ្លាយជ្រាបប្រេងឥន្ធនៈឬសាយភាយចំហាយឧស្ម័នចំហេះ

- មានប្រព័ន្ធការពាររន្ទះ ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ

- ស្ថិតនៅឆ្ងាយពីមន្ទីរពេទ្យ សាលារៀន មូលដ្ឋានកងទ័ព និងគោលដៅសំខាន់ៗផ្សេងទៀត ដែលមានហានិភ័យខ្ពស់ទៅតាមទំហំនៃបរិមាណស្តុកទុក

- មានស្លាកសញ្ញាណែនាំអំពីការបង្ការគ្រោះថ្នាក់អគ្គិភ័យ

- ត្រួតពិនិត្យជាប្រចាំ ដើម្បីទប់ស្កាត់ការបែកធ្លាយស៊ីទែនធុង ឬបំពង់បង្ហូរប្រេងឥន្ធនៈ និង/ឬឧស្ម័នចំហេះ

- បំពាក់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យតាមបទដ្ឋានបច្ចេកទេស ដែលទទួលស្គាល់ដោយអង្គភាពនគរបាលបង្ការពន្លត់អគ្គិភ័យ និងសង្គ្រោះ

- ហាមយកទីតាំងស្តុក ឬស្ថានីយប្រេងឥន្ធនៈ ឧស្ម័នចំហេះធ្វើជាកន្លែងកំសាន្តសប្បាយ ឬជួបជុំសម្រាប់រៀបចំពិធីផ្សេងៗ ។

បទដ្ឋានបច្ចេកទេសស្តីអំពីការបំពាក់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា១២.-**

អ្នកគ្រប់គ្រងគោលដៅលក់រាយប្រេងឥន្ធនៈ និង/ឬឧស្ម័នចំហេះត្រូវគោរពតាមលក្ខខណ្ឌ និងវិធានដូចខាងក្រោម៖

- ប្រកដប ឬធុងប្រេងឥន្ធនៈត្រូវមានបរិមាណសរុបតិចជាង ២០០លីត្រ

- ប្រកកំប៉ុង ឬធុងឧស្ម័នចំហេះ ត្រូវមានបរិមាណតិចជាង ១៥៣គីឡូក្រាម (ឬ៣០០លីត្រ)

- ត្រូវដាក់ដបទទេ ឬដាក់ស្លាកសញ្ញាមានលក់ប្រេងឥន្ធនៈ និង/ឬឧស្ម័នចំហេះ

- ដាក់នៅក្នុងធុង ឬដបដែលជាប់មាំល្អធានាមិនលេចធ្លាយធន់នឹងកម្តៅ មានប្រភពទឹក ហើយធានាថាមានសុវត្ថិភាព

- មានបំពង់ពន្លត់អគ្គិភ័យ និងឧបករណ៍សាមញ្ញសម្រាប់ត្រៀមបម្រុងពេលមានអគ្គិភ័យកើតឡើង

- ប្រកឬដាក់ឧស្ម័នចំហេះក្នុងធុង ឬកំប៉ុងដែលមានគុណភាពល្អធន់នឹងកម្តៅ

- ហាមប្រើប្រាស់ភ្លើងជិតកន្លែងលក់ប្រេងឥន្ធនៈ និង/ឬឧស្ម័នចំហេះ

- ហាមលក់ ឬស្តុកទុកប្រេងឥន្ធនៈ ឬឧស្ម័នចំហេះក្នុងផ្សារ និងបរិវេណផ្សារ

- ហាមយកលំនៅដ្ឋានធ្វើជាទីកន្លែងប្រកបអាជីវកម្មលក់ស្តុកទុកប្រេងឥន្ធនៈ និង/ឬឧស្ម័នចំហេះ

- គោរពលក្ខខណ្ឌ និងវិធានផ្សេងៗទៀតដែលពាក់ព័ន្ធការបង្ការ និងការពន្លត់អគ្គិភ័យ ដែលមានហានិភ័យខ្ពស់។

**មាត្រា១៣.-**

រាល់ទីកន្លែងផលិត កែច្នៃ និង/ឬស្តុកទុកសារធាតុងាយឆេះ ឬងាយផ្ទុះឆេះ ប្រភពភ្លើង ឬប្រភពកម្តៅ ដែលមានការផ្លាស់ប្តូរប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ ត្រូវស្នើសុំការអនុញ្ញាតជាមុនពីក្រសួងមហាផ្ទៃ ។

## ជំពូកទី៤

## សិទ្ធិ និងភារកិច្ចរបស់មន្ត្រីនគរបាល និងសមត្ថកិច្ចពាក់ព័ន្ធពន្លត់អគ្គិភ័យ

**មាត្រា១៤.-**

ក្នុងករណីមានអគ្គិភ័យកើតឡើង មន្ត្រីនគរបាល និង/ឬសមត្ថកិច្ចពាក់ព័ន្ធពន្លត់អគ្គិភ័យ ដឹកនាំបញ្ជាពន្លត់អគ្គិភ័យត្រូវ ៖

- សហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គភាពផ្សេងៗទៀតជួយសង្គ្រោះអាយុជីវិតមនុស្ស សត្វ ទ្រព្យសម្បត្តិបន្ទាន់ដើម្បីការពារសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈនៅក្នុង និងជុំវិញកន្លែង ដែលមានអគ្គិភ័យកើតឡើង
- សហការមួយអង្គភាពសុខាភិបាលចាត់វិធានការសង្គ្រោះបន្ទាន់នៅទីកន្លែង ដែលមានអគ្គិភ័យកើតឡើង
- កំណត់តំបន់ហាមឃាត់ការចេញចូលការឆ្លងកាត់ និងតំបន់ប្រតិបត្តិការពន្លត់អគ្គិភ័យ
- នគរបាលយុត្តិធម៌ ត្រូវស្រាវជ្រាវស៊ើបអង្កេតមូលហេតុដែលបង្កឱ្យមានអគ្គិភ័យ
- ធ្វើរបាយការណ៍ស្តីពីប្រតិបត្តិការពន្លត់អគ្គិភ័យ និងលទ្ធផលនៃការស្រាវជ្រាវពីមូលហេតុបង្កឱ្យមានអគ្គិភ័យ ។ ក្នុងករណីមានជាប់ពាក់ព័ន្ធបទល្មើសព្រហ្មទណ្ឌ មន្ត្រីនគរបាលបង្ការ និងពន្លត់អគ្គីភ័យ ដែលជាមន្ត្រីនគរបាលយុត្តិធម៌ ត្រូវកសាងសំណុំរឿងបញ្ជូនទៅព្រះរាជអាជ្ញាអមតុលាការរាជធានី ខេត្ត
- បញ្ចប់ការកំណត់តំបន់ហាមឃាត់ ការចេញចូល ការឆ្លងកាត់នៃតំបន់ប្រតិបត្តិការពន្លត់អគ្គិភ័យ ។

**មាត្រា១៥.-**

ក្នុងពេលប្រតិបត្តិការពន្លត់អគ្គិភ័យ មន្ត្រីនគរបាលបង្ការ និងពន្លត់អគ្គិភ័យ មានសិទ្ធិ ៖

- ចូលទៅក្នុងទីតាំងដែលមានអគ្គិភ័យកើតឡើង ហើយចាត់ចែងដោះស្រាយមធ្យោបាយ ឬសម្ភារ ដែលទទើសទទែងផ្លូវយកចេញ ឬវាយចោលវត្ថុ ឬកាត់ផ្តាច់ចេញនូវចំណែកនៃអគារ ឬអគារទាំងមូលដើម្បីទប់ស្កាត់ការរាលដាលនៃអគ្គិភ័យ
- ប្រើប្រាស់ឧបករណ៍មាននៅក្នុងទីតាំងកើតហេតុដែលយល់ឃើញថា ចាំបាច់ ដើម្បីពន្លត់អគ្គិភ័យ
- យកចេញនូវសម្ភារដែលគ្រោះថ្នាក់ងាយឆាបឆេះ ឬងាយផ្ទុះឆេះចេញពីគោលដៅដែលកំពុងមានអគ្គិភ័យ
- សហការជាមួយអង្គភាពផ្គត់ផ្គង់ទឹករបស់រដ្ឋ ឬឯកជន ឬប្រើប្រាស់ប្រភពទឹកទាំងក្នុង និងក្រៅគោលដៅប្រតិបត្តិការពន្លត់អគ្គិភ័យ
- បិទ ឬកាត់ផ្តាច់ ឬបញ្ជាឱ្យមានការកាត់ផ្តាច់ការផ្គត់ផ្គង់ឧស្ម័នចំហេះ ប្រេងឥន្ធនៈ សារធាតុងាយឆេះងាយផ្ទុះឆេះ ឬអគ្គិសនីនៅក្នុងទីតាំងដែលកំពុងមានអគ្គិភ័យកើតឡើង
- បិទ ឬសម្រួលការធ្វើចរាចរណ៍ដែលឋិតនៅតំបន់មានអគ្គិភ័យ
- គ្រប់គ្រង និងបញ្ជាកម្លាំងប្រតិបត្តិការទាំងអស់ ដែលមាននៅទីតាំងកើតមានអគ្គិភ័យ
- ចាត់វិធានការចាំបាច់ និងសមស្របដើម្បីការពារអាយុជីវិតមនុស្ស សត្វ ទ្រព្យសម្បត្តិសាធារណៈ ឯកជន និងសណ្តាប់ធ្នាប់សាធារណៈ។

**មាត្រា១៦.-**

មន្ត្រីនគរបាលបង្ការ និងពន្លត់អគ្គិភ័យអាចស្នើសុំឱ្យក្រុមហ៊ុនឯកជន ឬអង្គភាពផ្សេងដែលមានសម្ភារ ឬរថយន្តពន្លត់អគ្គិភ័យជួយអន្តរាគមន៍ពន្លត់អគ្គិភ័យក្នុងករណីចាំបាច់។

**មាត្រា១៧.-**

មន្ត្រីនគរបាល សមត្ថកិច្ចពាក់ព័ន្ធ និង/ឬជនណាដែលពលីជីវិត ឬរងរបួស ប៉ះពាល់សុខភាព ឬពិការមួយជីវិត ដែលរងគ្រោះក្នុងពេលប្រតិបត្តិការពន្លត់អគ្គិភ័យ នឹងទទួលបានការដោះស្រាយគោលនយោបាយផ្តល់កិត្តិយស និងផ្តល់ការព្យាបាលពីរដ្ឋដូចមានចែងក្នុងមាត្រា២៤ និងមាត្រា២៥ នៃច្បាប់ស្តីពីការបង្ការ និងពន្លត់អគ្គិភ័យ។

## ជំពូកទី៥
## ទោសប្បញ្ញត្តិ

**មាត្រា១៨.-**

មន្ត្រីនគរបាលបង្ការ និងពន្លត់អគ្គិភ័យមានសមត្ថកិច្ចត្រួតពិនិត្យ ព្រមានជាលាយលក្ខណ៍អក្សរ និងផាកពិន័យអន្តរការណ៍ចំពោះគ្រប់គោលដៅផលិតស្តុកទុកសារធាតុងាយឆេះ ឬងាយផ្ទុះឆេះ ប្រភពភ្លើង ឬប្រភពកម្តៅដែលមិនបានគោរព និងអនុវត្តតាមលក្ខខណ្ឌ និងវិធានបង្ការ និងពន្លត់អគ្គិភ័យដូចមានចែងក្នុងអនុក្រឹត្យនេះ។

ទម្រង់បែបបទនៃបង្កាន់ដៃផាកពិន័យអន្តរការណ៍ និងការគ្រប់គ្រងប្រាក់ចំណូល ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

នីតិវិធីនៃការចាត់ចែងប្រាក់ពិន័យដែលបានមកពីការផ្តន្ទាទោសដោយតុលាការ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា១៩.-**

នីតិបុគ្គល និងរូបវន្តបុគ្គលដែលទទួលខុសត្រូវគ្រប់គោលដៅស្តុកទុកសារធាតុងាយឆេះ ងាយផ្ទុះឆេះ ប្រភពភ្លើង ឬប្រភពកម្តៅ ដែលមិនគោរពអនុវត្តតាមបញ្ញត្តិនៃមាត្រា៩ ជំពូកទី៣ ស្តីពីលក្ខខណ្ឌ និងវិធានបង្ការ និងការពន្លត់អគ្គិភ័យនៃអនុក្រឹត្យនេះត្រូវ៖

- ព្រមានជាលាយលក្ខណ៍អក្សរ
- ក្នុងករណីមិនអនុវត្តតាមការព្រមាន ត្រូវពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី ១០.០០០.០០០ (ដប់លាន) រៀល
- ក្នុងករណីនៅតែមិនព្រមអនុវត្ត ត្រូវប្តឹងទៅតុលាការសុំឱ្យផ្អាកការធ្វើអាជីវកម្មជាបណ្តោះអាសន្ន ។

**មាត្រា២០.-**

អ្នកគ្រប់គ្រងមធ្យោបាយដឹកជញ្ជូនសារធាតុងាយឆេះ និងងាយផ្ទុះឆេះ ដែលមិនគោរពអនុវត្តតាមបញ្ញត្តិនៃមាត្រា១០នៃជំពូកទី៣ស្តីពីលក្ខខណ្ឌ និងវិធានបង្ការ និងការពន្លត់អគ្គិភ័យនៃអនុក្រឹត្យនេះត្រូវ៖

- ព្រមានជាលាយលក្ខណ៍អក្សរ
- ក្នុងករណីមិនអនុវត្តតាមការព្រមាន ត្រូវពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី ៤.០០០.០០០ (បួនលាន) រៀល
- ក្នុងករណីនៅតែមិនព្រមអនុវត្ត ត្រូវប្តឹងទៅតុលាការសុំឱ្យផ្អាកការធ្វើអាជីវកម្មជាបណ្តោះអាសន្ន ។

**មាត្រា២១.-**

អ្នកគ្រប់គ្រង/ម្ចាស់ស្ថានីយលក់ប្រេងឥន្ធនៈ សារធាតុងាយឆេះ និងងាយផ្ទុះឆេះ ដែលមិនគោរពអនុវត្ត តាមបញ្ញត្តិនៃមាត្រា១១ នៃជំពូកទី៣ស្តីពីលក្ខខណ្ឌ និងវិធានបង្ការ និងការពន្លត់អគ្គិភ័យនៃអនុក្រឹត្យនេះត្រូវ ៖

- ព្រមានជាលាយលក្ខណ៍អក្សរ

- ក្នុងករណីមិនអនុវត្តតាមការព្រមាន ត្រូវពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី ១០.០០០.០០០ (ដប់លាន)រៀល

- ក្នុងករណីនៅតែមិនព្រមអនុវត្ត ត្រូវប្តឹងទៅតុលាការសុំឱ្យផ្អាកការធ្វើអាជីវកម្មជាបណ្តោះអាសន្ន។

**មាត្រា២២.-**

អ្នកប្រកបអាជីវកម្មលក់រាយប្រេងឥន្ធនៈ សារជាតុងាយឆេះ និងងាយផ្ទុះឆេះ ដែលមិនគោរពតាម លក្ខខណ្ឌ និងវិធានបង្ការ និងការពន្លត់អគ្គិភ័យ ត្រូវអនុវត្តដូចមានចែងក្នុងមាត្រា១២ និងមាត្រា១៨នៃ អនុក្រឹត្យនេះត្រូវ៖

- ព្រមានជាលាយលក្ខណ៍អក្សរ

- ក្នុងករណីមិនអនុវត្តតាមការព្រមាន ត្រូវពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី ១.០០០.០០០ (មួយលាន)រៀល ។

**មាត្រា២៣.-**

ក្រៅពីពិន័យអន្តរការណ៍ដែលបានកំណត់នៅក្នុងអនុក្រឹត្យនេះ នីតិបុគ្គល និងរូបវន្តបុគ្គលដែលប្រព្រឹត្ត បទល្មើសទាក់ទងនឹងការបង្កឱ្យមានអគ្គិភ័យ ឬរាំងសកម្មភាពបង្ការ និងពន្លត់អគ្គិភ័យ ត្រូវផ្តន្ទាទោសតាម ច្បាប់ស្តីពីការបង្ការ និងការពន្លត់អគ្គិភ័យ និងទទួលទោសតាមច្បាប់ព្រហ្មទណ្ឌ។

## ជំពូកទី៦

## អន្តរប្បញ្ញត្តិ

**មាត្រា២៤.-**

ក្រសួងមហាផ្ទៃអាចសហការជាមួយដៃគូជាតិ និងអន្តរជាតិក្នុងការងារត្រួតពិនិត្យ និងអនុវត្តវិធាន បង្ការ និងពន្លត់អគ្គិភ័យ សំដៅជានាកាត់បន្ថយហានិភ័យគ្រោះថ្នាក់អគ្គិភ័យ និងការបំផ្លាញទ្រព្យសម្បត្តិឯកជន និងសាធារណៈដោយសារគ្រោះអគ្គិភ័យ។

**មាត្រា២៥.-**

ក្នុងរយៈពេល ២៤ខែ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន នីតិបុគ្គល ឬរូបវន្តបុគ្គលដែលផលិត កែច្នៃ ស្តុកទុក ដឹកជញ្ជូន គ្រប់គ្រងធ្វើពាណិជ្ជកម្មអាជីវកម្ម និងប្រើប្រាស់សារជាតុងាយឆេះ ឬងាយផ្ទុះឆេះ ប្រភពភ្លើង និងប្រភពកម្តៅ ត្រូវបំពេញទម្រង់បែបបទសុំវិញ្ញាបនបត្របញ្ជាក់អំពីគុណភាពប្រសិទ្ធភាពនៃប្រព័ន្ធ បង្ការ និងពន្លត់អគ្គិភ័យ និងកែតម្រូវឱ្យស្របតាមលក្ខខណ្ឌ និងវិធានបង្ការអគ្គិភ័យដូចមានចែងក្នុងអនុក្រឹត្យនេះ។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា២៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា២៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី

សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ២៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ